ការព្យាបាលរោគរបេង

លោកអ្នកនឹងប្រហែលជាចាប់ផ្តើមការព្យាបាលរោគរបេង (TB) ដែលមានរយៈពេលពីប្រាំមួយទៅប្រាំបួនខែ។ (ជួនកាលរយៈពេលព្យាបាល ប្រហែលជាត្រូវការពេលយូរជាងនេះទៅទៀត)។

ការឱយថ្នាំព្យាបាលរោគរបេង

ថ្នាំពេទ្យណាក៏អាចធ្វើប្រតិកម្មបានដែរ ដែលមានរួមទាំងថ្នាំព្យាបាលរោគរបេងផងដែរនោះ អាចនឹងបណ្តាលឱយមានឥទ្ធិពលបន្តាប់បន្សំ។ ចូរប្រើថ្នាំព្យាបាលទាំងអស់ទៅតាមការណែនាំនៃវេជ្ជបណ្ឌិតលោកអ្នក។ វេជ្ជបណ្ឌិតលោកអ្នកនឹងតាមដានឥទ្ធិពលនៃថ្នាំដែលគេចេញឱយណាមួយ ក្នុងការព្យាបាលស្ថានភាពរោគរបេងរបស់លោកអ្នក។ ប្រសិនណាជាកើតមានឥទ្ធិពលបន្តាប់បន្សំ លោកអ្នកគប្បីរាយការណ៍អំពីឥទ្ធិពលនោះទៅកាន់វេជ្ជបណ្ឌិតលោកអ្នកជាបន្ទាន់។
នៅពេលប្រើថ្នាំក្នុងរយៈពេលព្យាបាលរោគរបេង ឥទ្ធិពលបន្តាប់បន្សំខ្លះដែលគប្បីដឹង គឺ:

- រមាស់មិនចេះអស់មិនឈប់ឈរ។
- ឈឺពោះ ចេះតែចង់ក្អួត ឬមិនឃ្លានចំណីអាហារ។
- ឈឺស្រក្បែរដូចម្ជុលចាក់ ស្ពឹក ឬស្រពន់ទៅនឹងដៃឬជើង។
- ស្បែកមានស្នាមកន្ត្រួល ជាំ ឬពណិលឿង។
- ភ្នែកស្រវាំង។
- ទឹកម៉ូត្រមានពណិរាងខ្មៅ។

ហើយ / ឬ

- ភ្នែកពណិលឿង។

ថ្នាំពេទ្យតទៅនេះ ត្រូវបានប្រើឡើងដើម្បីព្យាបាលរោគរបេងហើយគឺជាថ្នាំគ្រាប់ដើម្បីលេប។

ISONIAZID

ថ្នាំ Isoniazid ប្រហែលជាធ្វើឱយលោកអ្នកមានអារម្មណ៍ហត់ទៀយ ប្រហែលជាបណ្តាលឱយចង់ក្អួត និងលែងឃ្លានចំណីអាហារ ហើយជាការដ៏កម្រដែរនោះ វាប្រហែលជាធ្វើឱយប្រអប់ដៃនិងជើងលោកអ្នក ស្ពឹក ឬ ស្រពន់។

RIFAMPICIN

ថ្នាំ Rifampicin អាចនឹងកាត់បន្ថយនូវប្រសិទ្ធិភាពនៃថ្នាំការពារកុំឲ្យមានកូន ។ ស្ត្រីដែលលេបថ្នាំការពារមិនឱយមានកូនត្រូវការប្រាប់វេជ្ជបណ្ឌិតរបស់ខ្លួនឲ្យបានដឹង មុននឹងចាប់ផ្តើមប្រើថ្នាំ Rifampicin ។ លោកអ្នកប្រហែលជាត្រូវការពិភាក្សាលើទម្រង់ការឯទៀតដើម្បីការពារមិនឱយមានកូន ជាមួយវេជ្ជបណ្ឌិតលោកអ្នកនៅឯមន្ទីរគម្រោងការណ៍គ្រួសារ។
បើសិនជាលោកអ្នកមានការរះកាត់ដាក់កែវភ្នែក ឬពាក់កែវទៅនឹងកែវភ្នែក (contact lens) ចូរប្រាប់វេជ្ជបណ្ឌិតលោកអ្នកដោយសារថ្នាំព្យាបាលនេះទំនងជាធ្វើឱយប្រឡាក់កែវទាំងនោះ។
ថ្នាំ Rifampicin នឹងបណ្តាលឱយពណិទឹកម៉ូត្រ ទឹកមាត់ និងញើស របស់លោកអ្នកទៅជាពណិផ្កាឈូកបន្តិចដែរ ប៉ុន្តែលោកអ្នកមិនគួរព្រួយបារម្ភឡើយ។

ETHAMBUTOL OR MYAMBUTOL

ទោះបីជាមន្ទីរព្យាបាលរោគដែលលោកអ្នកទៅជួបជាប្រក្រតី នឹងឆែកពិនិត្យមើលចក្ខុវិស័យរបស់លោកអ្នក ក៏លោកអ្នកត្រូវការប្រាប់វេជ្ជបណ្ឌិត ជាបន្ទាន់បើសិនជាលោកអ្នកចាប់ផ្តើមមានបញ្ហាទាក់ទងនឹងភាពមើលឃើញរបស់លោកអ្នក។ លោកអ្នកគួរឈប់លេបថ្នាំព្យាបាលរោគរបេងផងដែរ រហូតទាល់តែលោកអ្នកទទួលឱវាទពីវេជ្ជបណ្ឌិតលោកអ្នក។

PYRAZINAMIDE

ថ្នាំ Pyrazinamide ប្រហែលជាធ្វើឱយលោកអ្នកមានអារម្មណ៍ចង់ក្អួត និងបណ្តាលឱយលោកអ្នកមិនឃ្លានចំណី

អាហារ។ ជាធម្មតា គេប្រើថ្នាំ នេះនៅក្នុងពេលព្យាបាលពីរឬ បីខែដំបូងតែប៉ុណ្ណោះ។ ចូររាយការណ៍ពីការឈឺចាប់ ក្រួន ឬ កន្ត្តលស្បែកដែលមិនអាចពន្យល់បានណាមួយ ទៅកាន់ វេជ្ជបណ្ឌិតលោកអ្នកជាបន្ទាន់។

ចូរលេបថ្នាំឱយទ្បៀងទាត់

ជាការសំខាន់ណាស់ដែលលោកអ្នកត្រូវលេបថ្នាំព្យាបាលទាំង អស់ ដែលបញ្ជាដោយវេជ្ជបណ្ឌិតលោកអ្នក។ ការលេបថ្នាំមិន ទ្បៀងទាត់ ប្រហែលជាបណ្តាលឱយមានប្រតិកម្មយ៉ាងធ្ងន់ធ្ងរ និង បណ្តាលឱយថ្នាំបាត់បង់ប្រសិទ្ធិភាព។ ចូរច្បាស់រាងការបរិភោគ សុរា ដោយសារតែសុរាអាចបង្កើនជាតិពុលនៃថ្នាំ និង ឥទ្ធិពល បន្ទាប់បន្សំ។

ការធ្វើតេស្តក្នុងកម្លុងការព្យាបាលរោគ

វេជ្ជបណ្ឌិតលោកអ្នកប្រហែលជាសូមធ្វើតេស្តឈាមម្តងម្កាល ដើម្បីធ្វើឱយប្រាកដថា ថ្នាំលោកអ្នកកំពុងតែព្យាបាលរោគរបេង លោកអ្នកប្រកបដោយប្រសិទ្ធិភាព។
ការធ្វើតេស្តដទៃទ្បៀត ដូចជាតេស្តកំហាកនិងទឹកម៉ូត្រ ប្រហែល ជាធ្វើឡើងផងដែរដើម្បីឆែកពិនិត្យការរីកចំរើនរបស់លោកអ្នក។

ត្រូវការពត៌មានបន្ថែមទ្បៀត

ដើម្បីទទួលពត៌មានបន្ថែមទ្បៀត ចូរទាក់ទង :

TB Program
Disease Control Section
Department of Human Services
GPO Box 1670N
Melbourne 3001
ទូរស័ព្ទ : (03) 9637 4115

បោះផ្សាយដោយ Infectious Diseases Unit, Public Health Branch, Department of Human Services.
ពត៌មាននេះ គឺផ្អែកទៅលើដំណឹងដែលមានចុងក្រោយបង្អស់ នៅត្រឹមខែ មករា ឆ្នាំ 1998 ។
រៀបចំនិងផលិតដោយ Human Service Communications Unit ។
មាននៅតាម Internet នៅទីង http://hna.ffh.vic.gov.au